# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ ............១៤១............ក.ប/ប្រ.ក


# ប្រកាស

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញសារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការលើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១** : បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមួយដែលមានឈ្មោះថា "មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ" (មបវ.តឃ) ។ មជ្ឈមណ្ឌលនេះស្ថិតនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្រប់គ្រងផ្ទាល់ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ ។

**ប្រការ ២** : មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ មានភារកិច្ចៈ

- ធ្វើការប៉ាន់ប្រមាណ និងលើកគម្រោងតម្រូវការបណ្តុះបណ្តាល
- ធ្វើការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យឆ្លើយតបទៅនឹងតម្រូវការរបស់ខេត្ត និងតំបន់
- សហការជាមួយអង្គការនានាដើម្បីពង្រឹង និងពង្រីកការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ពីសកម្មភាពបណ្តុះបណ្តាលជូនមកក្រសួង តាមរយៈនាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- អនុវត្តតាមគោលការណ៍ណែនាំ សេចក្តីប្រកាស និងសារាចរណែនាំរបស់អភិបាលខេត្ត និងក្រសួង


អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ ៣** : មជ្ឈមណ្ឌលនេះ មានឋានៈស្មើនឹងការិយាល័យនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ។

**ប្រការ ៤** : នាយកមជ្ឈមណ្ឌលមានបុព្វសិទ្ធិស្មើនឹងប្រធានការិយាល័យនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ហើយមាននាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ប្រការ ៥** : ចំពោះមុខមជ្ឈមណ្ឌលមានផ្នែកការងារជាប្រចាំដូចតទៅ៖

១- ផ្នែករដ្ឋបាល និងបុគ្គលិក

២- ផ្នែកផែនការ និងហិរញ្ញវត្ថុ

៣- ផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៤- ផ្នែកស្រាវជ្រាវមុខរបរ និងទំនាក់ទំនងឧស្សាហកម្ម

៥- ផ្នែកបច្ចេកទេស និងអភិវឌ្ឍកម្មវិធីសិក្សា

ទៅថ្ងៃអនាគតមជ្ឈមណ្ឌលនេះ អាចស្នើសុំបង្កើតផ្នែកបន្ថែមទៀតតាមតម្រូវការជាក់ស្តែង ។

**ប្រការ ៦** : នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រធាននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ មានភារកិច្ចរៀងៗខ្លួនប្រតិបត្តិតាមប្រកាសនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

__ចម្លងជូន :__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ
- សាលាខេត្តត្បូងឃ្មុំ

**“ ដើម្បីជូនជ្រាប ”**

- គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**“ ដើម្បីផ្សព្វផ្សាយ និងអនុវត្ត ”**

- ឯកសារ-កាលប្បវត្តិ